ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិ
# ស្តីពី
# វិស័យផ្គត់ផ្គង់ទឹកស្អាត
# និងអនាម័យជនបទ ២០១១-២០២៥



ឯកសារសង្ខេប

ខែមេសា ឆ្នាំ២០១១





# មាតិកា


សេចក្តីផ្តើម ...... ១

ផ្នែកទី ១ - សាវតារ ...... ២

ផ្នែកទី ២ - ទស្សនវិស័យ ...... ៣

ផ្នែកទី ៣ - គោលបំណងនៃយុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ...... ៣

ផ្នែកទី ៤ - គោលដៅយុទ្ធសាស្ត្រ ...... ៤

ផ្នែកទី ៥ - បញ្ហាប្រឈមចម្បងនានានៃវិស័យ ...... ៥

ផ្នែកទី ៦ - គោលការណ៍ ...... ៦

ផ្នែកទី ៧ - សមាសភាគនៃយុទ្ធសាស្ត្រជាតិ ...... ៨

ផ្នែកទី ៨ - ការរៀបចំស្ថាប័ន តួនាទីនាំមុខនៃការផ្តល់សេវា និងតួនាទីនាំមុខនៃបរិយាកាសអំណោយផល ...... ១៦

# សេចក្ដីផ្ដើម

ឯកសារសង្ខេបនៃយុទ្ធសាស្ត្រជាតិស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ដែលហៅថា ឯកសារសង្ខេបយុទ្ធសាស្ត្រ ត្រូវបានចងក្រងឡើង ដើម្បីផ្ដល់សេចក្ដីសង្ខេបមួយ អំពីយុទ្ធសាស្ត្រជាតិស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០១១-២០២៥ ដែលត្រូវបានរៀបចំដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ឯកសារសង្ខេបនៃយុទ្ធសាស្ត្រជាតិ ស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានរៀបចំដូចខាងក្រោម :

ផ្នែកទី ១- សារតារផ្ដល់សេចក្ដីអធិប្បាយខ្លីមួយ អំពីស្ថានភាពទឹក និងអនាម័យបច្ចុប្បន្ននៅតំបន់ជនបទកម្ពុជា។

ផ្នែកទី ២- ទស្សនវិស័យគូសបង្ហាញអំពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលបានកំណត់ដោយរាជរដ្ឋាភិបាល។

ផ្នែកទី ៣- គោលបំណងនៃយុទ្ធសាស្ត្រជាតិស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ បង្ហាញគោលបំណងនៃយុទ្ធសាស្ត្រជាតិ។

ផ្នែកទី ៤- គោលដៅយុទ្ធសាស្ត្រ សង្ខេបគោលដៅយុទ្ធសាស្ត្រទាំងឡាយដែលមាននៅក្នុងយុទ្ធសាស្ត្រ។

ផ្នែកទី ៥- បញ្ហាប្រឈមចម្បងៗនៃវិស័យ ពិពណ៌នាបញ្ហាប្រឈមនានាដែលវិស័យជួបប្រទះ។

ផ្នែកទី ៦- គោលការណ៍ផ្ដល់ព័ត៌មានលម្អិតអំពីគោលការណ៍សំខាន់ៗ ដែលបំពេញមុខងារជាគ្រឹះសម្រាប់រៀបចំយុទ្ធសាស្ត្រ ក្នុងការសម្រេចបានទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

ផ្នែកទី ៧- សមាសភាគយុទ្ធសាស្ត្រអធិប្បាយគោលដៅនានា សម្រាប់ជំរុញសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ បរិយាកាសអំណោយផល និងហិរញ្ញប្បទាន លទ្ធផល និងសកម្មភាពរបស់វិស័យ ដែលរួមគ្នានឹងសម្រេចបាននូវទស្សនវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

ផ្នែកទី ៨ - ការរៀបចំស្ថាប័ន តួនាទីនាំមុខនៃការផ្ដល់សេវា និងតួនាទីនាំមុខនៃការរៀបចំបរិយាកាសសមស្រប (Enabling Environment) បង្ហាញការរៀបចំស្ថាប័នពាក់ព័ន្ធនានា តួនាទីនាំមុខក្នុងការផ្ដល់សេវា និងក្នុងការបង្កើតបរិយាកាសសមស្របមួយ។

ផ្នែកទី
១
# សាវតារ

រហូតមកដល់ពេលថ្មីៗនេះ លទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យមានការកែលម្អនៅតំបន់ជនបទកម្ពុជា នៅតែមានលក្ខណៈទាប និងមិនទំនងជាសម្រេចបានចំណុចដៅគ្របដណ្តប់ ១០០% មុនដំណាច់ឆ្នាំ២០២៥ ដូចដែលត្រូវបានព្យាករណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ នៅតំបន់ជនបទ លទ្ធភាពទទួលបានសេវាទឹកស្អាតមានការកែលម្អ គឺមានត្រឹមតែ ៥៣% ប៉ុណ្ណោះ (ក្នុងរដូវប្រាំង) និងការទទួលបានអនាម័យមាន ២៤% ក្នុងឆ្នាំ ២០១០ (អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ ២០១០)។ ៦៦% នៃប្រជាជននៅជនបទនៅតែអនុវត្តការបន្ទោបង់លាមកពាសវាលពាសកាល ដែលធ្វើឲ្យកខ្វក់ដល់បរិស្ថានដែលនៅជុំវិញ និងប្រភពទឹក។ ការទុកដាក់លាមកមិនសមស្របនេះ បូកជាមួយកង្វះការអនុវត្តអនាម័យ អាចនាំឲ្យមានការប៉ះពាល់ដល់សុខភាពរបស់ប្រជាជនទូទៅច្រើន។ ការខាតបង់ខាងសេដ្ឋកិច្ចប្រចាំឆ្នាំ ដោយសារអនាម័យមិនល្អនៅកម្ពុជា ត្រូវបានប៉ាន់ស្មានជាទឹកប្រាក់ចំនួន ៤៤៨ លានដុល្លារអាមេរិក ស្មើនឹង ៧,២% នៃផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ ២០០៥ (កម្មវិធីទឹកស្អាត និងអនាម័យ (WSP) ឆ្នាំ ២០០៨)។ ផលចំណេញពីការវិនិយោគលើអនាម័យ គឺមានច្រើនជាងទ្វេដងនៃថ្លៃចំណាយវិនិយោគ ពោល គឺទទួលបានជាង ២ ដុល្លារអាមេរិក ក្នុងប្រាក់វិនិយោគមួយដុល្លារ (WSP ឆ្នាំ ២០១២)។ ប៉ុន្តែសម្រាប់លទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ថ្វីបើវឌ្ឍនភាពមានលក្ខណៈប្រសើរជាងអនាម័យច្រើនក្តី ក៏គុណភាពទឹកច្រើនតែមិនមានសុវត្ថិភាព បើគ្មានការបន្សុទ្ធទឹកតាមផ្ទះបន្ថែម។ គេកត់សម្គាល់ថាការសម្រេចបានប្រកបដោយនិរន្តរភាពនូវគោលដៅនៃការគ្របជាសកលសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ តម្រូវឲ្យមានការកែលម្អវិធីសាស្ត្រផ្តល់សេវា ដែលមិនត្រឹមតែផ្តោតលើការផ្តល់គ្រឿងបរិក្ខារ ឬសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតលើការផ្លាស់ប្តូរឥរិយាបថ ឬយន្តការជំរុញភាពជាម្ចាស់ ដែលនាំទៅដល់ការប្រើប្រាស់សមស្រប ប្រតិបត្តិការ និងការថែទាំប្រព័ន្ធទៀតផង។

ផ្នែកទី ២

# ទស្សនវិស័យ

រាជរដ្ឋាភិបាលកម្ពុជា កំណត់ទស្សនវិស័យសម្រាប់វិស័យនេះ ដែលនៅក្នុងនោះ ប្រជាជនគ្រប់រូបនៅតាមសហគមន៍ជនបទមានលទ្ធភាពទទួលបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយសុវត្ថិភាព និងនិរន្តរភាព និងរស់នៅក្នុងបរិស្ថានមានអនាម័យនៅឆ្នាំ ២០២៥។ ទស្សនវិស័យនេះ ត្រូវបានលើកឡើងយ៉ាងច្បាស់នៅក្នុងគោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៣ដោយរាជរដ្ឋាភិបាលកម្ពុជា។ យុទ្ធសាស្រ្តជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០១១-២០២៥ ដែលហៅថាយុទ្ធសាស្រ្តជាតិ គឺសំដៅគាំទ្ររាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ។

ផ្នែកទី ៣

# គោលបំណងនៃយុទ្ធសាស្រ្តជាតិ ស្តីពីវិស័យ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

គោលបំណងនៃយុទ្ធសាស្រ្ត គឺសំដៅកំណត់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដែលត្រូវផ្តល់ជូនប្រជាជននៅតំបន់ជនបទ ការរៀបចំស្ថាប័នដែលបន្សុីគ្នាជាមួយនឹងកិច្ចដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (D&D) វិធីសាស្រ្តក្នុងការអនុវត្តកម្មវិធី ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលត្រូវការសម្រាប់ផ្តល់សេវាបន្ថែម និងរក្សាសេវាទាំងនេះឲ្យបានគង់វង្ស។

ផ្នែកទី
៤

# គោលដៅយុទ្ធសាស្ត្រ

គោលដៅយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រជាតិរបស់វិស័យ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ រួមមាន ៖

១. ការផ្គត់ផ្គង់ទឹកស្អាត ៖ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៥០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព។

២. បង្គន់អនាម័យ ៖ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៣០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យល្អ។

៣. ការលើកកម្ពស់អនាម័យ ៖ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៣០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងអនុវត្តទម្លាប់អនាម័យផ្ទាល់ខ្លួនបានល្អទាក់ទងនឹងការប្រើប្រាស់ទឹកស្អាត និងអនាម័យ។

៤. ការរៀបចំឲ្យមានបរិយាកាសសមស្រប ៖ នៅឆ្នាំ ២០១៥ ការរៀបចំស្ថាប័ន ឯកសារគតិយុត្តិ និងធនធានមនុស្ស ត្រូវបានរៀបចំឲ្យមានលក្ខណៈសមស្រប និងអាចបង្កើនការផ្តល់សេវាយ៉ាងលឿន និងរក្សាសេវាឲ្យបានគង់វង្ស។

៥. ហិរញ្ញប្បទាន ៖ ការផ្តល់មូលនិធិសម្រាប់ចំណាយមូលធនចរន្តនឹងមាន។

ផ្នែកទី ៥

# បញ្ហាប្រឈមចម្បងនានានៃវិស័យ

ការគ្រប់គ្រងវិស័យនៅមិនទាន់រឹងមាំនៅឡើយ : នៅថ្នាក់ជាតិនិងក្រោមជាតិ ស្ថាប័នរាជរដ្ឋាភិបាល អង្គការនានាចាំបាច់ត្រូវសម្របសម្រួលគ្នាឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

តួនាទី និងការទទួលខុសត្រូវនៅមិនទាន់មានលក្ខណៈប្រាកដប្រជាក្រោមកិច្ចដំណើរការវិមជ្ឈការ និងវិសហមជ្ឈការដែលកំពុងវិវត្ត : ស្ថាប័នរាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវដឹងច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនចំពោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។

ធនធានស្ថាប័ន និងធនធានមនុស្សសម្រាប់ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យប្រកបដោយនិរន្តរភាពក្នុងទ្រង់ទ្រាយធំ មានកម្រិតនៅឡើយ : ចាំបាច់ត្រូវត្រៀមលក្ខណៈឲ្យបានល្អនូវរចនាសម្ព័ន្ធស្ថាប័ន និងធនធានមនុស្សសមស្របក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាជនជាច្រើនដែលបច្ចុប្បន្នមិនមានលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ ក្នុងការរក្សាសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានស្រាប់ឲ្យនៅគង់វង្ស និងការជួយឲ្យប្រជាជនដែលគ្មានបង្គន់អនាម័យ អាចទិញ និងប្រើប្រាស់បង្គន់អនាម័យបាន។

ចំណាប់អារម្មណ៍ និងសមត្ថភាពរបស់វិស័យឯកជនក្នុងមូលដ្ឋាន ដើម្បីវិនិយោគលើសេវានិងផលិតផលផ្គត់ផ្គង់ទឹកស្អាត និងអនាម័យមានកម្រិតនៅឡើយ : ចាំបាច់ត្រូវមានបទប្បញ្ញត្តិច្បាស់លាស់ ដែលធានាបានការប្រកួតប្រជែងប្រកបដោយយុត្តិធម៌ ដែលលើកស្ទួយសមត្ថភាពធ្វើអាជីវកម្ម និងជួយសម្រួលលទ្ធភាពទទួលបានឥណទាន ដើម្បីទាក់ទាញការចូលរួមរបស់វិស័យឯកជននៅក្នុងវិស័យនេះ។

ការតាមដានវឌ្ឍនភាពនៃវិស័យ គឺមានលក្ខណៈពិបាកដោយសារកង្វះប្រព័ន្ធតាមដាន : ចាំបាច់ត្រូវមានការគ្រប់គ្រងប្រព័ន្ធព័ត៌មានមានបទដ្ឋានតែមួយដែលអនុញ្ញាតឲ្យមានការតាមដានវឌ្ឍនភាពរបស់វិស័យនេះ នៅតាមកម្រិតផ្សេងៗនៃរាជរដ្ឋាភិបាល។

ជម្រើសបច្ចេកវិទ្យាទាំងឡាយ ដែលសមសម្របសម្រាប់បរិស្ថានមានការលំបាក គឺមិនទាន់មាននៅឡើយទេៈ ការស្រាវជ្រាវ និងអភិវឌ្ឍន៍បន្ថែម គឺជាការចាំបាច់សម្រាប់ជម្រើសសេវាផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់រាំងស្ងួត ឬតំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក និងសម្រាប់បង្គន់ដែលមានតម្លៃថោក តែមាននិរន្តរភាពសម្រាប់ភូមិអណ្ដែតទឹក តំបន់មានទឹកជំនន់ និងតំបន់មានកម្រិតកម្ពស់ទឹកក្រោមដីខ្ពស់។

ផ្នែកទី
៦

# គោលការណ៍

និរន្តរភាព ៖ ការប្រើប្រាស់ជាបន្តនូវសំណង់ផ្គត់ផ្គង់ទឹក បង្គន់អនាម័យ និងការប្រកាន់យកឥរិយាបថអនាម័យជាទម្លាប់មួយ ដើម្បីឲ្យគ្រួសារនៅជនបទច្រើនជំនាន់ទទួលបានសុខភាពកាន់តែល្អប្រសើរឡើង និងមានជីវភាពប្រសើរឡើង។

ការគ្រប់គ្រងផ្អែកដោយសហគមន៍ ៖ ក្រុមតំណាងសហគមន៍ ដែលមានការចូលរួមដោយសមាជិកសហគមន៍ទាំងអស់ មានភាពជាម្ចាស់លើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានការទទួលខុសត្រូវលើការថែទាំ និងមានអំណាចក្នុងការធ្វើសេចក្ដីសម្រេចចិត្តជូនអ្នកប្រើប្រាស់។ សហគមន៍មានគណនេយ្យភាពលើសេចក្ដីសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួន។ ឧទាហរណ៍ សហគមន៍អាចសម្រេចចិត្តថាតើខ្លួនចង់ដំណើរការសេវាកម្មដោយខ្លួនឯង ឬចុះកិច្ចសន្យាការងារបន្តទៅឲ្យអ្នកផ្ដល់សេវាណាមួយក្នុងមូលដ្ឋាន។

វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ ៖ ការអភិវឌ្ឍសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅក្នុងសហគមន៍ណាមួយ ចាំបាច់ត្រូវផ្ដួចផ្ដើមដោយសហគមន៍នោះ។ សហគមន៍អាចស្នើសុំការជួយគាំទ្រពីស្ថាប័នពាក់ព័ន្ធ។ ពួកគេនឹងជ្រើសរើសយកសេវាដែលពួកគេចង់បាន និងអាចលៃលកបាន ដោយផ្អែកលើព័ត៌មានអំពីជម្រើសបច្ចេកវិទ្យាផ្សេងៗ ថ្លៃចំណាយ និងប្រតិបត្តិការ និងការថែទាំ។

ការចូលរួមបដិភាគសម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត ៖ សហគមន៍ធ្វើបដិភាគមួយផ្នែកលើថ្លៃចំណាយវិនិយោគលើការស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត ថ្លៃចំណាយមួយផ្នែក នៃសេវាគាំទ្រការថែទាំរបស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក

និងថ្លៃចំណាយទាំងស្រុងនៃប្រតិបត្តិការនិងការថែទាំ។ ក្រសួងអភិវឌ្ឍន៍ជនបទជាអ្នករៀបចំគោលការណ៍ណែនាំស្តីពីការចូលរួមបដិភាគ ហើយអាជ្ញាធរមូលដ្ឋានកំណត់ទំហំបដិភាគ ដែលសហគមន៍ត្រូវបង់សម្រាប់ការស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត និងការចំណាយសម្រាប់សេវាគាំទ្រការថែទាំ។

ការផ្តល់ហិរញ្ញប្បទានអនាម័យ : គ្រួសារនីមួយៗ នឹងចំណាយថវិកាផ្ទាល់របស់គេសម្រាប់សង់បង្គន់អនាម័យរបស់ខ្លួន។ ហិរញ្ញវត្ថុសាធារណៈ ត្រូវប្រើសម្រាប់តែដើម្បីបង្កើតតម្រូវការអនាម័យ និងលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថអនាម័យឲ្យកាន់តែប្រសើរឡើង និងដើម្បីជួយសម្រួលវិស័យឯកជន ក្នុងការផ្តល់សេវាអនាម័យ និងលើកស្ទួយសមត្ថភាពរបស់ស្ថាប័នថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលក្នុងការជំរុញ សម្របសម្រួល តាមដាន និងរាយការណ៍អំពីវឌ្ឍនភាពនៃការអន្តរាគមន៍អនាម័យ។ ការឧបត្ថម្ភធនផ្ទាល់ជាសម្ភារសម្រាប់ការសង់បង្គន់អាចត្រូវបានប្រើតែក្នុងលក្ខខណ្ឌមានគោលដៅច្បាស់លាស់ ដើម្បីជួយគាំទ្រប្រជាជនក្រីក្រតែប៉ុណ្ណោះ។

សមាហរណកម្មនៃការជំរុញសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ : នៅទីណាដែលមិនមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដែលមានការកែលម្អវិធីសាស្ត្រចម្រុះដែលជំរុញសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ គប្បីត្រូវបានប្រើ។ ប៉ុន្តែប្រសិនបើការផ្គត់ផ្គង់ទឹកស្អាតមានការកែលម្អមានវត្តមានរួចហើយ គេគប្បីប្រើតែវិធីសាស្ត្រជំរុញអនាម័យបានហើយ។

ប្រតិបត្តិការ និងការថែទាំ (O&M): ក្រុមប្រើប្រាស់ទឹក និងអនាម័យ (WSUG) ទទួលខុសត្រូវលើប្រតិបត្តិការ និងការថែទាំសំណង់ផ្គត់ផ្គង់ទឹកស្អាតរបស់សហគមន៍។ ក្រុមប្រើប្រាស់ទឹក និងអនាម័យ អាចស្វែងរកការជួយគាំទ្រខាងបច្ចេកទេសពីសេវាគាំទ្រប្រតិបត្តិការ និងថែទាំ នៅថ្នាក់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ។ ការថែទាំបង្គន់តាមផ្ទះ គឺជាការទទួលខុសត្រូវរបស់គ្រួសារនីមួយៗ។

វិមជ្ឈការ និងវិសហមជ្ឈការនៃការផ្តល់និងការគ្រប់គ្រងសេវា : រាល់ការផ្តល់និងការគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទាំងអស់ ត្រូវគោរពតាមក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥) និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ (ឆ្នាំ ២០០៨)។

គុណនេយ្យភាព ៖ នៅពេលអភិវឌ្ឍ ដំណើរការ និងការតាមដានសេវា និងនៅពេលរៀបចំគម្រោង កម្មវិធី ឬសកម្មភាពផ្សេងទៀត ស្ថាប័នទទួលបន្ទុក (រដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល) ចាំបាច់ត្រូវពិចារណាអំពីប្រការដែលថាៈ តើលទ្ធផលនៃការងារ ឬសកម្មភាពរបស់ពួកគេប៉ះពាល់យ៉ាងដូចម្តេចលើអ្នកទទួលផលនៃសេវាកម្មទាំងនេះ និងលើយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ការបញ្ជ្រាបយេនឌ័រ ៖ បញ្ហាយេនឌ័រចាំបាច់ត្រូវពិចារណានៅពេលរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃគោលនយោបាយ និងការផ្តល់សេវានៅគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចទាំងអស់។

ការបញ្ជ្រាបពិការភាព ៖ សេវាទាំងអស់ គប្បីគោរពតាមច្បាប់ស្តីពីកិច្ចគាំពារ និងលើកកម្ពស់សិទ្ធិជនពិការ (ឆ្នាំ២០០៩)។ សេចក្តីត្រូវការរបស់ជនពិការ គប្បីត្រូវបានពិចារណានៅក្នុងគ្រប់ដំណាក់កាល នៃការអភិវឌ្ឍសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។

ផ្នែកទី ៧

# សមាសភាគនៃយុទ្ធសាស្ត្រជាតិ

## គោលដៅយុទ្ធសាស្ត្រទី ១ - បង្កើនលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត មានភាពតែលម្អប្រកបដោយនិរន្តរភាព

### សមាសភាគ ១.១ - កំណើនលទ្ធភាពទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត

**សំណង់ផ្គត់ផ្គង់ទឹកស្អាតថ្មី ដោយប្រើមូលនិធិពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ៖** រៀបចំបញ្ជីសារពើភ័ណ្ឌនៃសេវានៅថ្នាក់ជាតិ និងខេត្ត ដើម្បីយល់ឲ្យបានកាន់តែប្រសើរឡើងថាតើសំណង់ផ្គត់ផ្គង់ទឹកស្អាតថ្មីគឺចាំបាច់នៅទីណាខ្លះ។ ការស្នើសុំសំណង់ថ្មីគប្បីធ្វើឡើងសហគមន៍ ហើយក្រុមប្រើប្រាស់ទឹក និងអនាម័យ គប្បីត្រូវបង្កើតឡើង។

**ស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ ដោយប្រើមូលនិធិពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ៖** ធ្វើការសិក្សាដើម្បីយល់ដឹងពីវិសាលភាព និងមូលហេតុដែលនាំឲ្យហេដ្ឋារចនាសម្ព័ន្ធទាំងនោះខូចកន្លងមក និងរៀបចំគោលការណ៍ណែនាំសម្រាប់ការ

ស្តារឡើងវិញ។ ការស្នើសុំសំណង់ការស្តារឡើងវិញ គប្បីធ្វើឡើងសហគមន៍ ហើយក្រុមប្រើប្រាស់ទឹក និងអនាម័យ គប្បីត្រូវបង្កើតឡើង។

**រិះរកបច្ចេកវិទ្យាដែលមានលក្ខណៈសមស្រប៖** ធ្វើការស្រាវជ្រាវ ការអភិវឌ្ឍបច្ចេកវិទ្យា និងសេវាសមស្រប ដើម្បីធ្វើឲ្យគេអាចរកបានបច្ចេកវិទ្យាផ្គត់ផ្គង់ទឹកស្អាត មានតម្លៃថោក សម្រាប់តំបន់រាំងស្ងួត និងតំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក និងសម្រាប់តម្រូវការសង្គម ដូចជាជនពិការជាដើម។

**លើកទឹកចិត្តវិស័យឯកជន៖** សហការជាមួយវិស័យឯកជន ដើម្បីចែករំលែកហានិភ័យគ្នាក្នុងការផ្តល់សេវានៅតំបន់ជួបការលំបាក និងដាច់ស្រយាល។

## សមាសភាគ ១.២ - ការអនុវត្តបទដ្ឋានគុណភាពទឹក

**អភិវឌ្ឍនីតិវិធីសម្រាប់កម្មវិធីផ្គត់ផ្គង់ទឹកស្អាត ដើម្បីអនុលោមតាមបទដ្ឋានគុណភាពទឹក ៖** អភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកថ្នាក់ខេត្ត និងបង្កើតផែនការសុវត្ថិភាពទឹកនៅថ្នាក់ឃុំ។ នីតិវិធីនានាដែលឆ្លើយតបទៅនឹងចំណុចប្រភពទឹក ដែលមិនគោរពតាមបទដ្ឋានគុណភាពទឹកក៏ចាំបាច់ត្រូវបង្កើតឡើងផងដែរ។

**ជំរុញការការពារគុណភាពទឹក ៖** ជំរុញការអនុវត្តការយកទឹកប្រកបដោយសុវត្ថិភាព ចាប់តាំងប្រភពទឹករហូតដល់ចំណុចប្រើប្រាស់ ដោយផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍ជំរុញអនាម័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ បង្កើតពិធីសារផ្ទៀងផ្ទាត់បច្ចេកវិទ្យាបរិស្ថាន (ETV) សម្រាប់បច្ចេកវិទ្យាបន្សុទ្ធទឹកតាមផ្ទះ ដើម្បីធានាឲ្យបានថាបច្ចេកវិទ្យាដែលមាននៅក្នុងទីផ្សារ គឺមានប្រសិទ្ធភាពក្នុងការផ្តល់ទឹកផឹកមានសុវត្ថិភាព។

## សមាសភាគ ១.៣ - ការកែលម្អនៅក្នុងប្រតិបត្តិការ និងការថែទាំ

**ជំរុញប្រតិបត្តិការ និងការថែទាំរបស់សហគមន៍៖** ពង្រឹងការគ្រប់គ្រងរបស់សហគមន៍លើប្រតិបត្តិការ និងការថែទាំ តាមរយៈការជួយគាំទ្រក្រុមប្រើប្រាស់ទឹក និងអនាម័យក្នុងការទទួលយកតួនាទី និងការទទួលខុសត្រូវនេះ។ បង្កើតប្រព័ន្ធគាំទ្រការថែទាំនៅតាមការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីផ្តល់ការជួយគាំទ្រជូនក្រុមប្រើប្រាស់ទឹក និងអនាម័យពាក់ព័ន្ធនឹងការផ្តល់បច្ចេកទេស ការបណ្តុះបណ្តាល និងការបង្វឹក។

## សមាសភាគ ១.៤ - កំណើនទីផ្សារសម្រាប់ផលិតផលទឹកស្អាត និងអនាម័យ (WASH)

លម្អខ្សែសង្វាក់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (WASH) បង្កើតគម្រោងមួយអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់សម្រាប់ស្ទប់ដៃ និងផលិតផលផ្គត់ផ្គង់ទឹកស្អាត និងអនាម័យផ្សេងទៀត ដើម្បីឲ្យសហគមន៍ និងគ្រួសារអាចទិញពីផ្សារក្នុងមូលដ្ឋានបាន។

## គោលដៅយុទ្ធសាស្ត្រទី ២ - ការបង្កើនលទ្ធភាពទទួលបានអនាម័យដែលមានការកែលម្អ

### សមាសភាគ ២.១ - ការបង្កើនលទ្ធភាពទទួលបានអនាម័យ

**ជំរុញការប្រកាន់យក និងការប្រើបង្គន់ :** ប្រើវិធីសាស្ត្រផ្លាស់ប្តូរឥរិយាបថអនាម័យនានា (ឧទាហរណ៍សហគមន៍ដឹកនាំអនុវត្តន៍អនាម័យទាំងស្រុង (CLTS) និងជំរុញទីផ្សារក្នុងមូលដ្ឋាន ដើម្បីផ្តល់ផលិតផល និងសេវាអនាម័យ ដើម្បីឲ្យគ្រួសារទិញ ស្ថាបនា និងប្រើបង្គន់។

ជំរុញជម្រើសអនាម័យផ្សេងៗ ធ្វើការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍ ឬអនុម័តយកជម្រើស និងបច្ចេកវិទ្យាអនាម័យផ្សេងៗ ដើម្បីធ្វើឲ្យសេវាផ្គត់ផ្គង់បង្គន់អនាម័យអាចរកបាន និងមានតម្លៃថោកសម្រាប់គ្រួសារក្រីក្រ រួមទាំងអ្នកដែលរស់នៅតាមតំបន់ឧស្សាហ៍មានទឹកជំនន់ និងភូមិអណ្តែតទឹក។

### សមាសភាគ ២.២ - ការកែលម្អនៅក្នុងប្រតិបត្តិការ និងការថែទាំ

ជំរុញប្រតិបត្តិការ និងការថែទាំតាមផ្ទះ៖ គ្រួសារទទួលបន្ទុកលើប្រតិបត្តិការ និងការថែទាំបង្គន់អនាម័យរបស់ពួកគេ។

**អភិវឌ្ឍសេវាបូមកាកសំណល់ចេញពីរណ្តៅបង្គន់ :** អភិវឌ្ឍនីតិវិធីច្បាស់លាស់សម្រាប់ការគ្រប់គ្រងអាងស្តុកលាមក ការបូមកាកសំណល់ចេញពីរណ្តៅបង្គន់ ការបន្សុទ្ធ ការបោះបង់ចោល និងការប្រើឡើងវិញនូវកាកសំណល់រណ្តៅបង្គន់។ សហការជាមួយវិស័យឯកជនដើម្បីអភិវឌ្ឍសេវានេះ ដោយមានការបណ្តុះបណ្តាលសមស្របពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាជធានី និងស្ថាប័នជំនាញនានា ។

### សមាសភាគ ២.៣ - ការកែលម្អអនាម័យនៅតាមសាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នជនបទផ្សេងទៀត

**ជំរុញអនាម័យសាលារៀន :** រៀបចំបទដ្ឋាន ដើម្បីកំណត់ចំនួនសិស្ស និងបុគ្គលិកសម្រាប់បង្គន់នីមួយៗ ដោយយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ និងពិការភាព។ រៀបចំបញ្ជីសារពើភ័ណ្ឌសំណង់ផ្គត់ផ្គង់ទឹក និងសំណង់បង្គន់អនាម័យ ដែលដំណើរការល្អ ដើម្បីអាចកំណត់អាទិភាព។ រាប់បញ្ចូលការអប់រំអនាម័យជាផ្នែកមួយនៃកម្មវិធីសិក្សា ដោយក្រសួងអប់រំ យុវជន និង កីឡា។ ការផ្តល់សំណង់ ចាំបាច់ត្រូវផ្អែកលើតម្រូវការ។

**ជំរុញអនាម័យនៅតាមមណ្ឌលសុខភាព :** រៀបចំបទដ្ឋាន ដើម្បីកំណត់ចំនួនអ្នកជំងឺសម្រាប់បង្គន់អនាម័យនីមួយៗ ដោយយកចិត្តទុកដាក់ដល់បញ្ហាយេនឌ័រ និងពិការភាព។

រៀបចំបញ្ជីសារពើភ័ណ្ឌសំណង់ផ្គត់ផ្គង់ទឹក និងសំណង់បង្គន់ដែលដំណើរការល្អ ដើម្បីអាចកំណត់អាទិភាព។ ការផ្តល់សំណង់ចាំបាច់ត្រូវផ្អែកលើតម្រូវការ។

**គ្រប់គ្រងកាកសំណល់ប្រកបដោយសុវត្ថិភាព :** ប្រើវិធីសាស្ត្រស្អិទ្ធនឹងបរិស្ថាន ដើម្បីគ្រប់គ្រងទឹកសំណល់ និងកាកសំណល់រឹង។ ចំណុចនេះចាំបាច់ត្រូវទទួលព័ត៌មានពីការសិក្សាដែលវាយតម្លៃទំហំនៃបញ្ហាជាមួយសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ។

## គោលដៅយុទ្ធសាស្ត្រទី ៣ - កែលម្អឥរិយាបថអនាម័យ

### សមាសភាគ ៣.១ - ការជំរុញអនាម័យ

**បង្កើនការយល់ដឹងរបស់ប្រជាជនអំពីការប្រើអនាម័យមានសុវត្ថិភាព:** ផ្សព្វផ្សាយ និងជំរុញការអនុវត្តគោលការណ៍ជំរុញអនាម័យរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ធ្វើយុទ្ធនាការផ្លាស់ប្តូរឥរិយាបថអនាម័យឲ្យបានទៀងទាត់នៅតាមសហគមន៍ តាមរយៈការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ ជាមួយគណៈកម្មាធិការសម្រាប់នារី និងកុមារ (CCWC) ឃុំ សង្កាត់ ដោយផ្អែកលើយុទ្ធសាស្ត្រទំនាក់ទំនង ដើម្បីការផ្លាស់ប្តូរឥរិយាបថ។

## គោលដៅយុទ្ធសាស្ត្រទី ៤ - សម្រេចបានសេវាប្រកបដោយនិរន្តរភាព

### សមាសភាគ ៤.១ - ការកែលម្អនៅក្នុងការគ្រប់គ្រងវិស័យ

**អភិវឌ្ឍផែនការសម្រាប់ការកែលម្អស្ថាប័ន** : សម្របសម្រួល និងគ្រប់គ្រងសកម្មភាពទាំងឡាយដែលចាំបាច់សម្រាប់ការកែលម្អស្ថាប័ន និងអភិវឌ្ឍផែនការអនុវត្តច្រើនឆ្នាំជាមួយក្របខណ្ឌតាមដានច្បាស់លាស់។

**សម្របសម្រួលគ្រប់គ្រង និងតាមដានការផ្តល់សេវានៅថ្នាក់ស្រុក** : ពង្រឹងការិយាល័យអភិវឌ្ឍន៍ជនបទស្រុកខណ្ឌ ក្នុងស្រុកខណ្ឌនីមួយៗ ដោយមានការជួយគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាជធានី។

**កំណត់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់** : ផ្សព្វផ្សាយប្រកាសកំណត់តួនាទីរបស់ស្ថាប័ននៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។

**បង្កើនគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន** : ដាក់ឲ្យអនុវត្តយន្តការគណនេយ្យភាពតាមមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តាមរយៈគោលការណ៍ណែនាំ និងនីតិវិធីរបស់ក្រសួងអភិវឌ្ឍន៍ជនបទ រួមទាំងប្រព័ន្ធមួយ ដែលនៅក្នុងនោះ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ អាចចាត់ចែងការតវ៉ាណាមួយពីសហគមន៍ប្រកបដោយប្រសិទ្ធភាព។

**ដាក់បញ្ចូលបទដ្ឋានសម្រាប់គណនេយ្យភាពក្នុងការអភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធីនានា ដើម្បីធានាការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព** : ពិនិត្យមើលគោលការណ៍ណែនាំមានស្រាប់ និងអភិវឌ្ឍគោលការណ៍ណែនាំថ្មី ដើម្បីឆ្លុះបញ្ចាំងបទដ្ឋានគណនេយ្យ-ភាព។

### សមាសភាគ ៤.២ - ធនធានមនុស្ស និងអភិវឌ្ឍន៍សមត្ថភាព

**ពង្រឹងសមត្ថភាពរបស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ ដើម្បីជួយសម្រួល និងរក្សាសេវាឲ្យបានគង់វង្ស**:រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពពេញលេញ សម្រាប់ការិយា-ល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដោយសម្របសម្រួលជាមួយវិស័យដទៃទៀត និងកិច្ចដំណើការវិមជ្ឈការ និងវិសហមជ្ឈការ និងពង្រឹងសមត្ថភាពរបស់បុគ្គលិកការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ ដោយមានការជួយគាំទ្រពីថ្នាក់ខេត្ត និងជាតិ។

## សមាសភាគ ៤.៣ - គាំទ្រការអភិវឌ្ឍវិស័យឯកជន

**បង្កើតបរិយាកាសប្រកួតប្រជែងមួយ** : អភិវឌ្ឍ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវគោលការណ៍ណែនាំ ដែលបង្ហាញគោលការណ៍នៃការទទួលខុសត្រូវគណនេយ្យភាព ភាពអាចព្យាករណ៍បាន និងតម្លាភាពសម្រាប់វិស័យឯកជនដែលចូលរួមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ។ ដាក់ឲ្យអនុវត្តកិច្ចសន្យាផ្តល់សេវារយៈពេលវែង (យ៉ាងហោចណាស់ ១០ ឆ្នាំ) ដែលនៅក្នុងនោះ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដោយវិស័យឯកជនគឺចាំបាច់។

**កសាងសមត្ថភាព និងកែលម្អលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់វិស័យឯកជន** : អភិវឌ្ឍបទប្បញ្ញត្តិច្បាស់លាស់ ដែលជួយគាំទ្រអាជីវកម្មក្នុងមូលដ្ឋានក្នុងការទទួលបានប្រាក់កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុ។ផ្តល់ការបណ្តុះបណ្តាលសមស្របស្តីពីអាជីវកម្មជាមូលដ្ឋាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ជូនអាជីវកម្មក្នុងមូលដ្ឋាន។

## សមាសភាគ ៤.៤ - ការកែលម្អនៅក្នុងការធ្វើផែនការ និងប្រព័ន្ធព័ត៌មានគ្រប់គ្រង

**បង្កើតការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS) រួមមួយ** : ធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានបច្ចុប្បន្នជាមួយនឹងទិន្នន័យផ្សេងៗ សម្រាប់បង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ ដែលអាចប្រើបាននិងរួមចំណែកបានដោយភាគីពាក់ព័ន្ធទាំងអស់។ ប្រព័ន្ធតាមដានរួមនេះ គប្បីតាមដានវឌ្ឍនភាពនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ ការដំណើរការ ការប្រើប្រាស់ និងឥរិយាបថពាក់ព័ន្ធ។

## សមាសភាគ ៤.៥ - ការវាយតម្លៃ និងការសិក្សា

**ជំរុញការសិក្សានិងការចែករំលែកចំណេះដឹង** : ធ្វើការសិក្សាទៀងទាត់អំពីទិដ្ឋភាពជាក់លាក់នានា ឬការវាយតម្លៃបទពិសោធន៍នៅក្នុងវិស័យនេះ និងបង្កើតវេទិកាសម្រាប់ចែករំលែកចំណេះដឹង (ឧទាហរណ៍ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (WatSan Sectoral Coordination Working Group))។

## សមាសភាគ ៤.៦ - ការស្រាវជ្រាវការអភិវឌ្ឍ និងការច្នៃប្រឌិត

**បង្កើតនីតិវិធីសម្រាប់ជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត** : បង្កើតនីតិវិធីជាលក្ខណៈប្រព័ន្ធសម្រាប់អនុវត្តការធ្វើពិសោធន៍ ការអនុម័ត និងផ្សព្វផ្សាយអំពីវិធីសាស្ត្រ និងការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។

### សមាសភាគ ៤.៧ - ការកែលម្អនៅក្នុងទំនាក់ទំនង

**កែលម្អទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនៅក្នុងនិងនៅក្រៅវិស័យ ៖** អភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រទាក់ទង ដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះនយោបាយ និងសាធារណៈសម្រាប់វិស័យនេះ។

### សមាសភាគ ៤.៨ - ការរាប់បញ្ចូលភាពក្រីក្រ ជនជាតិភាគតិច និងភាពងាយរងគ្រោះ

**គាំទ្រការផ្តល់សេវាជូនប្រជាជនក្រីក្រ ៖** ផ្តល់អាទិភាពជូនដល់គ្រួសារក្រីក្របំផុត និងងាយរងគ្រោះបំផុតសម្រាប់ការផ្តល់សេវា តាមរយៈបញ្ជីកំណត់អត្តសញ្ញាណនៃគ្រួសារក្រីក្រ។

**ធានាឲ្យបាននូវការផ្តល់សេវាដែលរាប់បញ្ចូលពិការភាព ៖** ឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងកង្វល់របស់ជនពិការ ដោយផ្អែកលើច្បាប់ស្តីពីកិច្ចគាំពារ និងការលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ២០០៩ និងរាប់បញ្ចូលពួកគេនៅក្នុងការអភិវឌ្ឍ ការអនុវត្ត និងការតាមដានសេវា។

### សមាសភាគ ៤.៩ - ការបញ្ជ្រាបយេនឌ័រ

**បញ្ជ្រាបយេនឌ័រនៅក្នុងវិស័យ ៖** ពិនិត្យឡើងវិញ និងកែសម្រួល ប្រសិនបើចាំបាច់នូវគោលការណ៍ណែនាំ និងនីតិវិធីវិស័យមានស្រាប់ និងថ្មីទាំងអស់ ដើម្បីធានាឲ្យបានថា ៖ គោលការណ៍ណែនាំ និងនីតិវិធីវិស័យទាំងនេះ ត្រូវបានដោះស្រាយគ្រប់គ្រាន់នូវបញ្ហាយេនឌ័រ។ អភិវឌ្ឍវគ្គសិក្សាតម្រង់ទិសយេនឌ័រ ដែលសមស្របសម្រាប់អ្នកធ្វើការក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយសហការជាមួយក្រសួងកិច្ចការនារី។

### សមាសភាគ ៤.១០ - បរិស្ថាន

**សម្រាលផលប៉ះពាល់បរិស្ថានក្នុងការអភិវឌ្ឍ និងការផ្តល់សេវា ៖** សិក្សា និងស្វែងយល់ពីផលប៉ះពាល់បរិស្ថាននៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅគ្រប់កម្រិត និងអភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធីនានា ដើម្បីសម្រាលផលប៉ះពាល់បរិស្ថាន។

### សមាសភាគ ៤.១១ - បម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ

**បង្កើនភាពស្វាហាប់នៃសេវា ៖** អភិវឌ្ឍសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ និងហានិភ័យនៃបម្រែបម្រួលអាកាសធាតុ តាមរយៈការអភិវឌ្ឍលក្ខណៈបច្ចេកទេសសមស្រប និងការសម្របសម្រួលជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## គោលដៅយុទ្ធសាស្ត្រទី ៥ - បង្កើនហិរញ្ញប្បទានរបស់វិស័យ

### សមាសភាគ ៥.១ - កំណើនហិរញ្ញប្បទានថ្លៃចំណាយមូលធន

**បង្កើនការផ្តល់មូលនិធិសម្រាប់ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាតថ្មី និងស្តារនីតិសម្បទាសំណង់ផ្គត់ផ្គង់ទឹកស្អាតមានស្រាប់៖** អភិវឌ្ឍផែនការវិនិយោគលើវិស័យនេះ តស៊ូមតិឲ្យមានការបង្កើនមូលនិធិគាំទ្រពីរាជរដ្ឋាភិបាល និងជំរុញការចូលរួមបដិភាគពីសហគមន៍។

**អភិវឌ្ឍយន្តការហិរញ្ញប្បទានអនាម័យ ៖** អភិវឌ្ឍ សាកល្បង និងវាយតម្លៃយន្តការផ្តល់មូលនិធិផ្សេងៗ ក្រោមការណែនាំនៃក្រុមដឹកនាំមួយ ដើម្បីកំណត់យន្តការដែលផ្តល់ប្រកបដោយប្រសិទ្ធភាពបំផុតនូវលទ្ធភាពទទួលសេវាប្រកបដោយនិរន្តរភាព ដែលរាប់បញ្ចូលប្រជាជនក្រីក្រ ការពារសុខភាពសាធារណៈ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន។

**ផ្តល់មូលនិធិសម្រាប់អភិវឌ្ឍសមត្ថភាពគ្រប់គ្រងរបស់ស្ថាប័ន និងវិស័យឯកជន ៖** ប៉ាន់ស្មានថ្លៃចំណាយ ដែលត្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការអភិវឌ្ឍវិស័យឯកជន។ តស៊ូមតិដើម្បីបង្កើនការផ្តល់មូលនិធិពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

### សមាសភាគ ៥.២ - បង្កើនហិរញ្ញប្បទានថ្លៃចំណាយចរន្ត

**ផ្តល់មូលនិធិសម្រាប់រក្សាសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យឲ្យនៅគង់វង្ស ៖** បង្កើតមូលនិធិថែទាំនៅសហគមន៍ ដែលត្រូវបានចូលរួមបដិភាគដោយគ្រួសារ និងត្រូវបានគ្រប់គ្រងដោយក្រុមប្រើប្រាស់ទឹក និងអនាម័យ ដើម្បីបង់ថ្លៃចំណាយប្រតិបត្តិការទាំងស្រុងនៃសេវាផ្គត់ផ្គង់ទឹកស្អាត និងដើម្បីបង់ថ្លៃសម្រាប់សេវាគាំទ្រ ការថែទាំរបស់ការិយាល័យអភិវឌ្ឍន៍ជនបទ ស្រុក ខណ្ឌ។ គ្រួសារនឹងរ៉ាប់រងថ្លៃចំណាយសម្រាប់ប្រតិបត្តិការ និងការថែទាំបង្គន់របស់ពួកគេ រួមទាំងអាងស្តុកលាមក និងការយកកាកសំណល់ចេញពីរណ្តៅបង្គន់។

បង្កើនហិរញ្ញវត្ថុពីស្ថាប័នថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល អាជ្ញាធរថ្នាក់ស្រុក ខណ្ឌ និងឃុំ សង្កាត់ វិភាជន៍ថវិកាសម្រាប់សេវាគាំទ្រការថែទាំរបស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ និងសម្រាប់បន្តការជំរុញអនាម័យ។

ផ្នែកទី
៨

# ការរៀបចំស្ថាប័ន តួនាទីនាំមុខនៃការផ្តល់សេវាតួនាទីនាំមុខនៃបរិយាកាសអំណោយផល

ការរៀបចំស្ថាប័ន គឺជាតួនាទីឯកភាពគ្នាមួយ សម្រាប់ក្រសួង/ស្ថាប័នរាជរដ្ឋាភិបាល (ថ្នាក់ជាតិ និងក្រោមជាតិ) សមាជិកសហគមន៍/គ្រួសារ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឲ្យបានថាមានបរិយាកាសអំណោយផល ហើយសេវាត្រូវបានផ្តល់។ បរិយាកាសអំណោយផល គឺជាគោលនយោបាយ ឧបករណ៍ហិរញ្ញវត្ថុ អង្គការនានាជា (ទទួលស្គាល់ជាផ្លូវការ) អង្គការសហគមន៍ និងភាពជាដៃគូ ដែលគួបផ្សំចូលគ្នា ដើម្បីគាំទ្រ និងជំរុញការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាពតម្លៃ។ ការផ្តល់សេវា គឺនៅពេលណាដែលក្រសួង/ស្ថាប័នរាជរដ្ឋាភិបាល (ថ្នាក់ជាតិ និងក្រោមជាតិ) និង ឬ អាជីវកម្មឯកជនអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ខ្លួន ដើម្បីផ្តល់ "សេវា" បានទៅដល់ប្រជាជន និងទីកន្លែងដែលសេវាត្រូវបានគ្រោង និងនៅទីណាដែលគេត្រូវការសេវា។

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| **កម្រិតជាតិ** | ❖ **ក្រសួងអភិវឌ្ឍន៍ជនបទ** ដោយសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត ទទួលខុសត្រូវលើ :<br>• គោលនយោបាយ/យុទ្ធសាស្ត្រ។<br>• ធ្វើផែនការវិស័យ។<br>• តាមដានវិស័យ និងបទប្បញ្ញត្តិ។<br>• សម្របសម្រួលជំនួយ។<br>• ជំនួយបច្ចេកទេសសម្រាប់អភិវឌ្ឍធនធានមនុស្ស សិក្សាស្រាវជ្រាវ/ការសាកល្បង។ | ❖ **ក្រសួងអភិវឌ្ឍន៍ជនបទ** ដឹកនាំការអភិវឌ្ឍយុទ្ធនាការ និងឯកសារ ស្តីពីការផ្លាស់ប្តូរឥរិយាបថ ដោយផ្អែកលើភស្តុតាង។<br>❖ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍ និងការធ្វើផែនការ។<br>❖ **ដៃគូអភិវឌ្ឍន៍** ផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍ និងការធ្វើផែនការ និងផ្តល់ឱវាទបច្ចេកទេស។<br>❖ **ក្រុមហ៊ុនខ្លួង** ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត។<br>❖ **ឈ្មួញពាណិជ្ជកម្ម** ចែកចាយ និងលក់ទឹកស្អាត និងផលិតផលអនាម័យ។ | ❖ **ក្រសួងអភិវឌ្ឍន៍ជនបទ :**<br>• សហការជាមួយក្រសួងមហាផ្ទៃ ផ្តល់នីតិកម្ម និងគោលនយោបាយ។<br>• ធ្វើនិយ័តកម្មនីតិកម្ម និងគោលនយោបាយ។<br>• សម្របសម្រួលជាមួយដៃគូអភិវឌ្ឍ គោលការណ៍ណែនាំ និងនីតិវិធីរបស់វិស័យ។<br>• សម្របសម្រួលជាមួយដៃគូ ធ្វើការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍធនធានមនុស្ស។<br>• អភិវឌ្ឍការរៀនសូត្រតាមរយៈការវាយតម្លៃ និងការស្រាវជ្រាវ ការសាកល្បង និងការបញ្ជាក់។ |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| | | | ❖ **ដៃគូអភិវឌ្ឍន៍**<br>• ផ្តល់ឱវាទបច្ចេកទេសសម្រាប់អភិវឌ្ឍនីតិកម្ម និងគោលនយោបាយ។<br>• ផ្តល់ឱវាទបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធី។<br>• ផ្តល់ឱវាទបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីការបណ្តុះបណ្តាលធនធានមនុស្ស។<br>• ផ្តល់ឱវាទបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីជំរុញបរិយាកាសប្រកួតប្រជែងសម្រាប់វិស័យឯកជន។<br>• ផ្តល់ឱវាទបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីជួយគាំទ្រអាជីវកម្ម និងជំនាញបច្ចេកទេស ជូនវិស័យឯកជន។<br>• ធ្វើការស្រាវជ្រាវ ការសាកល្បង និងការបញ្ជាក់ ដើម្បីរួមចំណែកដល់របៀបវារៈនៃការរៀនសូត្រវិស័យ។ |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| | | | ❖ **គ្រឹះស្ថានហិរញ្ញវត្ថុ** ផ្តល់ការវិនិយោគ និងប្រាក់កម្ចី តាមការចាំបាច់។<br>❖ **អ្នកពិគ្រោះយោបល់ :** ផ្តល់សេវាពិគ្រោះយោបល់ដើម្បីធ្វើការវាយតម្លៃ តាមការចាំបាច់ ក្នុងការរួមចំណែកដល់របៀបវារៈរៀនសូត្រ។<br>❖ **គ្រឹះស្ថានសិក្សា/ស្ថាប័នបណ្តុះបណ្តាល** ផ្តល់សេវា ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស តាមតម្រូវការរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ |
| **កម្រិតខេត្ត** | ❖ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដោយមានការជួយគាំទ្រពីអាជ្ញាធរថ្នាក់ខេត្ត និងក្រសួងពាក់ព័ន្ធផ្សេងទៀត :<br>• ណែនាំការអនុវត្តយុទ្ធសាស្ត្រនៅក្នុងខេត្ត រាជធានី។<br>• ពិនិត្យមើលឲ្យបានប្រាកដថាកម្មវិធីធ្វើតាមគោលការណ៍នៃយុទ្ធសាស្ត្រជាតិ។ | ❖ **មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត រាជធានី :**<br>• ទទួលខុសត្រូវលើការរៀបចំផែនការសម្រាប់បង្កើតតម្រូវការ។<br>• តាមដាន និងផ្តល់ឱវាទបច្ចេកទេសសម្រាប់ការផ្តល់សំណង់ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។<br>• តាមដានប្រតិបត្តិការនៃសំណង់។ | ❖ **គ្រឹះស្ថានហិរញ្ញវត្ថុ / គ្រឹះស្ថានហិរញ្ញវត្ថុ** ផ្តល់ការវិនិយោគ និងប្រាក់កម្ចី។<br>❖ **អង្គការមិនមែនរដ្ឋាភិបាល** ធ្វើការវាយតម្លៃវិស័យ ដើម្បីរួមចំណែកដល់ការរៀនសូត្រ។<br>❖ **គ្រឹះស្ថានបណ្តុះបណ្តាល** ផ្តល់ការបណ្តុះបណ្តាលធនធានមនុស្ស។ |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| | • ផ្តល់ឱវាទបច្ចេកទេស ជូនការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ និងគាំទ្រការអនុវត្ត។<br>• ប្រមូល និងរាយការណ៍ទិន្នន័យនៃការតាមដាន និងការវាយតម្លៃ។<br>• បណ្តុះបណ្តាល និងពង្រឹងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ខណ្ឌ ក្នុងការអនុវត្តការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យរបស់ខ្លួន។<br>• ជួយសម្រួលការចូលរួមរបស់វិស័យឯកជននៅក្នុងសេវាអនាម័យ។ | ❖ **ដៃគូអភិវឌ្ឍន៍** ផ្តល់ធនធានសម្រាប់ការអភិវឌ្ឍ និងការធ្វើផែនការ។<br>❖ **គ្រឹះស្ថានហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ផ្តល់មូលនិធិដែលចាំបាច់។<br>❖ **អ្នកផលិត និងអ្នកម៉ៅការ**<br>• ចែកចាយ និងលក់ទឹក និងផលិតផលអនាម័យ។<br>• ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។<br>❖ **ក្រុមហ៊ុនខួង** ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត។ | |
| **កម្រិតស្រុក ខណ្ឌ** | ❖ ការិយាល័យអភិវឌ្ឍន៍ជនបទ ស្រុក ខណ្ឌ :<br>• ទទួលការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេសពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាជធានី។ | ❖ **អភិបាលស្រុក ខណ្ឌ :**<br>• ប្រតិបត្តិ និងត្រួតពិនិត្យអនុលោមជាមួយនឹងបទប្បញ្ញត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ទឹក និងផលិតផលអនាម័យ ដែលត្រូវបានលក់ដោយវិស័យឯកជន។ | |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| | • សហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាជធានី ក្នុងការប្រមូលទិន្នន័យវិស័យសម្រាប់ការគ្រប់គ្រងប្រព័ន្ធព័ត៌មាន (MIS)។<br>• សហការជាមួយរដ្ឋបាលស្រុក ខណ្ឌ (មន្ត្រីក្រុមប្រឹក្សាស្រុក ខណ្ឌ និង គណៈអភិបាលស្រុកខណ្ឌ) ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់។<br>• ត្រួតពិនិត្យគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធថ្មី និងហេដ្ឋារចនាសម្ព័ន្ធស្តារឡើងវិញ។<br>• ផ្តល់ការជួយគាំទ្រប្រតិបត្តិការជូនក្រុមប្រើប្រាស់ទឹក និងអនាម័យ។<br>• ពិនិត្យមើលគុណភាពនៃការផ្គត់ផ្គង់ទឹកស្អាត ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រើប្រាស់ទឹក និងអនាម័យ<br>• ណែនាំ និងសហការជាមួយគណៈកម្មាការផិការសម្រាប់នារី និងកុមារ (CCWC) ឃុំ សង្កាត់ ដើម្បីអនុវត្តអនាម័យ និងការជំរុញយុទ្ធនាការអនាម័យ។ | • ប្រតិបត្តិ និងត្រួតពិនិត្យអនុលោមជាមួយនឹងបទប្បញ្ញត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ការស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។<br>• ទទួលខុសត្រូវលើប្រតិបត្តិការនៃប្រព័ន្ធគាំទ្រការថែទាំរបស់ការិយាល័យអភិវឌ្ឍន៍ជនបទ ស្រុក ខណ្ឌ។<br>❖ **អ្នកផលិតក្នុងមូលដ្ឋាន :**<br>• ចែកចាយ និងលក់ទឹក និងផលិតផលអនាម័យ។ | |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| **កម្រិតឃុំ សង្កាត់** | ❖ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្នើសុំ និងដឹកនាំការជួយរបស់ការិយាល័យអភិវឌ្ឍន៍ជនបទ ស្រុក ខណ្ឌ។<br>❖ CCWC ធ្វើយុទ្ធការផ្សព្វផ្សាយអនាម័យ និងការបណ្តុះបណ្តាលអនាម័យជាមួយសហគមន៍។ | ❖ **អ្នកម៉ៅការឯកជន** ចែកចាយ និងលក់ទឹក និងផលិតផលអនាម័យ<br>❖ **សិប្បករក្នុងភូមិ :**<br>• ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត និងបង្គន់។<br>• ថែទាំ/ជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។<br>• សហការជាមួយប្រព័ន្ធគាំទ្រការថែទាំរបស់សហគមន៍។<br>❖ **ក្រុមជាងម៉ាស៊ីនក្នុងភូមិ** ស្ថាបនាសំណង់ផ្គត់ផ្គង់ទឹកស្អាត។ | |
| **កម្រិតសហគមន៍/ភូមិ** | ❖ ក្រុមប្រើប្រាស់ទឹកស្អាត និងអនាម័យ :<br>• ធ្វើការធានាឲ្យការផ្គត់ផ្គង់ទឹកស្អាតមានសុវត្ថិភាព និងមានការកែលម្អ។<br>• ធ្វើការជាមួយគ្រួសារ និងសហគមន៍ ដើម្បីបង់ថ្លៃជួសជុលនៃសេវាផ្គត់ផ្គង់ទឹកស្អាត។<br>• ធ្វើការជាមួយសមាជិកគ្រួសារ និងសហគមន៍ ដើម្បីបង់ថ្លៃ ដើម្បីធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាត មានដំណើរការ មានសុវត្ថិភាព មានការកែលម្អ និងប្រើប្រាស់ឲ្យបានយូរអង្វែង។ | ❖ **សមាជិកសហគមន៍ :**<br>• ប្រតិបត្តិការ និងថែទាំ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។<br>• ប្រើប្រព័ន្ធគាំទ្រការថែទាំ និងចូលរួមក្នុងការជំរុញអនាម័យ។ | |

| | ការរៀបចំស្ថាប័ន<br>កំណត់សម្គាល់ : ដើម្បីភាពច្បាស់លាស់តួនាទីរបស់វិស័យឯកជន មិនត្រូវបានដាក់បញ្ចូលក្នុងជួរបញ្ឈរនេះទេ | តួនាទីនាំមុខនៃការផ្តល់សេវា | តួនាទីនាំមុខនៃបរិយាកាសអំណោយផល |
|---|---|---|---|
| **កម្រិតគ្រួសារ** | ❖ សមាជិកគ្រួសារ :<br>• ទិញ និងប្រើបង្គន់អនាម័យ<br>• ថែទាំឲ្យបង្គន់អនាម័យរបស់ខ្លួនដំណើរការស្អាត និងមានការកែលម្អឲ្យប្រើប្រាស់បានយូរអង្វែង។<br>• រក្សាគេហដ្ឋាន និងបរិស្ថានជុំវិញគេហដ្ឋានពួកគេឲ្យបានស្អាត។<br>• ប្រកាន់យកទម្លាប់អនាម័យ ដូចជាការលាងដៃជាមួយសាប៊ូជាដើម។ | ❖ សមាជិកគ្រួសារ ប្រើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ | |

## ក្រសួងអភិវឌ្ឍជនបទ

កែងផ្លូវ ១៦៩ និងមហាវិថីសហព័ន្ធរុស្សី
ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (៨៥៥) ២៣ ៨៨៤ ៥៣៩
ទូរសារ : (៨៥៥) ២៣ ៩៩១ ១១៧
គេហទំព័រ : www.mrd.gov.kh



ឧបត្ថម្ភដោយ :

ADB unicef wsp water and sanitation program